# ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល

ចូរអានសេចក្ដីរាយការណ៍សារព័ត៌មានមួយដូចខាងក្រោមនេះ ។




សៀមរាប : ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័លឆ្នាំ ២០១០នេះ បានប្រារព្ធឡើងកាលពីថ្ងៃទី២ ខែឧសភា នៅទីលានជល់ដំរី ខេត្តសៀមរាប ។ ពិធីនេះ ត្រូវបានប្រព្រឹត្តធ្វើឡើងយ៉ាងគគ្រឹកគគ្រេងជាទីបំផុត ក្រោមព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងមានការចូលរួមផងដែរ ពីសំណាក់ឥស្សរជនជាន់ខ្ពស់ ថ្នាក់ដឹកនាំព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល ព្រមទាំងប្រជាពលរដ្ឋ សិស្សានុសិស្ស និងមន្ត្រីរាជការមកពីគ្រប់ទិសទីយ៉ាងច្រើនកុះករ ។

ព្រះរាជពិធី បានចាប់ផ្ដើមនៅវេលាម៉ោងប្រមាណជា៨ និង ៣០នាទីព្រឹក ដោយមានព្រះអង្គម្ចាស់ស៊ីសុវត្ថិវិជ្ជារាវុធទ្រង់ជាស្ដេចមាឃ យាងច្រត់ព្រះនង្គ័ល ភ្ជួរព្រះស្រែ និងអ្នកអង្គម្ចាស់ក្សត្រីនរោត្តមរស្មីពនីតាទ្រង់ជាព្រះមេហួ ។ ព្រះរាជពិធីនេះ បានប្រព្រឹត្តទៅចំនួនបីជុំនៃវាលព្រះស្រែ ។ បន្ទាប់មក ក្រុមបាគូបានដឹកគោឧសភរាជទៅកាន់ថាសមាសដែលមានអាហារ និងទឹកចំនួនប្រាំពីរថាស ពោលគឺស្រូវមួយថាស ពោតមួយថាស ល្ងមួយថាស សណ្ដែកមួយថាស ស្មៅមួយថាស ទឹកមួយថាស និងស្រាមួយថាសផងដែរ ។ជាលទ្ធផល គោឧសភរាជបានទទួលទានគ្រាប់ពោតច្រើនជាងគេ បន្ទាប់មកគឺសណ្ដែកដែលជាប្រផ្នូលទាយថា ការបង្កបង្កើនផលឆ្នាំនេះ ពោតទទួលបានផលល្អ និងសណ្ដែកទទួលបានផលល្អបង្គួរ ។



ពិធីនេះ ត្រូវបានប្រារព្ធឡើងរៀងរាល់ឆ្នាំ នៅពេលរដូវវស្សាចាប់ផ្ដើម ហើយក្រុមព្រះបរោហិតអះអាងថា ការផ្សងប្រផ្នូលតាមរយៈគោឧសភរាជនៅក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័លនេះ មានតាំងពីបុរាណកាលមក ។

(ដកស្រង់ពីកាសែតរស្មីកម្ពុជាលេខ៥១៨៨ថ្ងៃអង្គារ ទី០៤ ខែឧសភា ឆ្នាំ២០១០)

## សំណួរ

១. តើព្រះរាជពិធីច្រត់ព្រះនង្គ័លឆ្នាំ២០១០នេះ ប្រារព្ធធ្វើនៅឯណា ? តើអ្នកណាខ្លះចូលរួម ?
២. តើគេបានធ្វើសកម្មភាពអ្វីខ្លះ នៅក្នុងព្រះរាជពិធីបុណ្យនេះ ?
៣. តើមានទឹកនិងអាហារអ្វីខ្លះ សម្រាប់ផ្សងគោឧសភរាជ ?
៤. តើគោឧសភរាជបរិភោគអ្វី ?
៥. តើគេផ្សងគោឧសភរាជដើម្បីអ្វី ?
៦. តើអត្ថបទនេះនិយាយអំពីអ្វី ?

## លំហាត់

ក. ចូរបំពេញល្បះខាងក្រោមឱ្យបានសមស្រប ។

១. រៀងរាល់ឆ្នាំ ព្រះរាជពិធីច្រត់ព្រះនង្គ័លបានប្រារព្ធនៅ............... ។
២. នៅពេលបញ្ចប់ពិធីភ្ជួរព្រះស្រែ មានពិធីផ្សង...................... ។
៣. អាហារសម្រាប់ផ្សងគោឧសភរាជមាន.............មុខគឺ............ ។
៤. អាហារទាំងនេះ គេដាក់នៅក្នុង.................................. ។
៥. ព្រះរាជពិធីនេះ ប្រារព្ធនៅរដូវ................................... ។

ខ. ចូរចម្លងសេចក្ដីដកស្រង់សម្ដី ដែលមាននៅក្នុងអត្ថបទសារព័ត៌មានខាងលើ ។